## ៥. លទ្ធផល និងការពិភាក្សា

### ៥-១ អំពីរុក្ខជាតិ

**៧៤.** តាមរយៈការសិក្សាលើឡូតិ៍គំរូបានបង្ហាញថា មានប្រភេទឈើសរុបចំនួន១២៦ប្រភេទ ស្មើនឹង៣៩៤ដើម តិណជាតិចំនួន៩៨ប្រភេទ ស្មើនឹង៤៨៣ដើម ប្រភេទស្មៅនិងដុល្លព្រឹកចំនួន៣៣ប្រភេទស្មើនឹង៣៩២ដើម **(ឧបសម្ព័ន្ធ៥ : តារាង៥-១ ប្រភេទសារពើរុក្ខជាតិ ដែលជួបប្រទះនៅក្នុងតំបន់សម្បទានរ៉ែរបស់ក្រុមហ៊ុន)**។ ភាពសម្បូរណ៍បែប និងសមាសភាពនៃរុក្ខជាតិទាំងនោះ ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការពន្យល់ បកស្រាយពីរចនាសម្ព័ន្ធទីជំរក ដោយលោក Sceweithelm and Chhay 2007 ដោយបាននិយាយថា នៅក្នុងព្រៃល្បោះគ្របដណ្តប់ដោយប្រភេទរុក្ខជាតិដូចជា ខ្លុង ត្បែង ផ្ចឹក រាំងភ្នំ នាងផ្អែក ក្នុងពេលដែលពពួកស្បូវ និងស្មៅព្រិច ជាពពួករុក្ខជាតិថ្នាក់ក្រោម។

### ៥-២ អំពីសត្វព្រៃ

**៧៥.** ការសិក្សាបានបង្ហាញថា មានសត្វស្លាបចំនួន ៣៨ ប្រភេទស្មើនឹង ២០៦ក្បាលត្រូវបានកត់ត្រា។ ក្នុងចំណោមពពួកសត្វស្លាបទាំងអស់ ប្រភេទសត្វស្លាបដែលមានវត្តមានច្រើនជាងគេគឺសេកអាត់ ពពិចក្បាលខ្មៅ ចុងខ្នងស និងសេកសក។ ក្រៅពីនេះមានប្រភេទដែលមានវត្តមានបង្គួរដូចជា សេកក្រិច និងពពួកចាបជង្ហូរ **(ឧបសម្ព័ន្ធ៥ : តារាង៥-២ ប្រភេទ និងចំនួនសត្វស្លាបដែលមាននៅក្នុងតំបន់សម្បទានរ៉ែរបស់ក្រុមហ៊ុន)**។ លទ្ធផលនេះក៏ស្រប តាម Tan and Pool, 2003, FA and CI, 2004 ដែលពណ៌នាថា ប្រភេទទាំងនេះជាប្រភេទមានដោយបង្គួរ នៅក្នុងប្រទេសកម្ពុជា។

**៧៦.** តារាង៥-១ ខាងក្រោមបានបង្ហាញឱ្យឃើញថា ភាពសំបូរបែបនៃសត្វស្លាបដែលបានកត់ត្រានៅក្នុងតំបន់សិក្សាស្រាវជ្រាវ គឺមានចំនួនស្មើនឹង៤១ភាគរយ នៃលទ្ធផលដែលទទួលបានពីការសំភាសន៍ជាមួយប្រជាជនមូលដ្ឋានដែលរស់នៅក្បែរតំបន់សិក្សាស្រាវជ្រាវ ហើយស្មើនឹង២១ភាគរយ នៃចំនួនសត្វស្លាបដែលបានកត់ត្រានៅតំបន់ព្រៃការពារជួរភ្នំក្រវាញភាគកណ្តាល នឹងត្រូវជា០៦ភាគរយ នៃចំនួនសត្វស្លាបសរុបក្នុងប្រទេសកម្ពុជា។

**៧៧.** មានថនិកសត្វចំនួន ២២ប្រភេទត្រូវបានកត់ត្រា **(ឧបសម្ព័ន្ធ៥ : តារាង៥-៣ ប្រភេទថនិកសត្វ ដែលមានវត្តមាននៅក្នុងតំបន់សម្បទានរ៉ែរបស់ក្រុមហ៊ុន)**។ ក្នុងចំណោមពពួកថនិកសត្វទាំងអស់នេះមានឈ្លូស និងជ្រូកព្រៃ ត្រូវបានចាត់ថាជាប្រភេទមានដោយបង្គួរ (MAFF,2007)។ តារាងលេខដដែលនេះ ក៏បានបង្ហាញអោយឃើញផងដែរថា ថនិកសត្វដែលកត់ត្រាបានមានចំនួនប្រមាណ៥៤ភាគរយ នៃចំនួនសត្វដែលបាន ពីលទ្ធផលសំភាសន៍ប្រជាជនមូលដ្ឋាន ហើយត្រូវជា២៩ភាគរយ នៃចំនួនថនិកសត្វដែលបានកត់ត្រានៅតំបន់ព្រៃការពារជួរភ្នំក្រវាញភាគកណ្តាល និងប្រមាណ១០ភាគរយនៃចំនួន ថនិកសត្វសរុបនៅក្នុងប្រទេសកម្ពុជា។

៧៨. មានដានចាស់ៗរបស់សត្វដំរីព្រៃត្រូវបានគេប្រទះឃើញ និងកត់ត្រាតែនៅក្នុងតំបន់ Border I nig II នៃឡូតិ៍របស់ក្រុមហ៊ុន។ តាមរយៈអ្នកនាំផ្លូវបានឱ្យដឹងថា សត្វដំរីទាំងនោះតែងតែមកព្រៃតំបន់នេះក្នុងរដូវប្រាំងជាពិសេសក្នុងខែមីនារហូតដល់ខែឧសភា ដែលតំបន់ផ្សេងទៀតគ្មានទឹកសម្រាប់ពួកវារស់នៅ។ ទោះជាយ៉ាងណាក៏ដោយ មានដានជើង និងលាមកថ្មីៗរបស់សត្វខ្ទីង ត្រូវបានប្រទះឃើញនិងកត់ត្រានៅក្នុងតំបន់ Border II នៃឡូតិ៍ របស់ក្រុមហ៊ុនដែលតំបន់នោះមានដីច្រាប និងល្បាប់ភក់សំរាប់សំរាប់សត្វព្រៃទាំងពួង។ ប៉ុន្តែមានដានចាស់ៗ របស់សត្វខ្ទីង ក៏ត្រូវបានប្រទះឃើញនិងកត់ត្រានៅក្នុងតំបន់ Border I នៃឡូតិ៍របស់ក្រុមហ៊ុនផងដែរ។ លើសពីនេះនៅមានដានថ្មីៗដូចជា ដានប្រើស ខ្លាត្រី ស្វាព្រាម ក៏បានជួបប្រទះ និងកត់ត្រានៅក្នុងតំបន់ព្រៃល្បោះនៃតំបន់ Border III របស់ក្រុមហ៊ុន។

**តារាង៥-១ : ការប្រៀបធៀបពីភាពសំបូរបែបរបស់សត្វស្លាប និងថនិកសត្វនៅក្នុងតំបន់សិក្សាស្រាវជ្រាវ ទៅនឹងលទ្ធផលពីការសិក្សាសនីនៅតំបន់ជួរភ្នំក្រវាញភាគកណ្តាល និងទូទាំងប្រទេស**

| ប្រភេទ | តំបន់សិក្សាស្រាវជ្រាវ | ពីការសំភាសន៍ | តំបន់ជួរភ្នំក្រវាញភាគកណ្តាល | ទូទាំងប្រទេស |
|---|---|---|---|---|
| សត្វស្លាប | ៣៨ | ៩៣ | ១៨៤ | ៦៣០ |
| ថនិកសត្វ | ២២ | ៤១ | ៧៦ | ២១៨ |

*ប្រភព : ម៉ែន សូរិយាន់ និងអ្នកដទៃទៀត ២០០២, Jenny and Frank 2000*

## ៥-៣ អំពីមច្ឆាជាតិ

៧៩. នៅក្នុងតំបន់សម្បទានរ៉ែមិនសំបូរប្រភពទឹកស្រទាប់លើទេ ពោលគឺមានតែស្ទឹងដាស់ ដែលស្ថិតនៅតាមបណ្តោយព្រំខាងលិចរបស់តំបន់ OTT និង OMN-2 និងដៃស្ទឹងតូចៗចំនួនពីរ របស់ស្ទឹងកំពង់ល្ពៅ (ប្រព័ន្ធផ្លូវទឹកខាងលើរបស់ព្រែកស្រែអំបិល) ដែលស្ថិតនៅនឹងមាត់ព្រំប្រទល់ខាងកើតរបស់តំបន់ OMN-1 ប៉ុណ្ណោះ។ តាមការសាកសួរពីប្រជាពលរដ្ឋនៅក្នុងតំបន់បញ្ជាក់ថា ពួកគាត់ធ្លាប់នេសាទបាននូវប្រភេទត្រីមួយចំនួន (ទាំងប្រភេទត្រីស និងត្រីខ្មៅ) នៅក្នុងតំបន់នោះ។ ប្រភេទត្រីសំខាន់ៗ ដែលពួកគាត់ធ្លាប់នេសាទមានដូចជា: **(១) ត្រីស:** ត្រីឆ្ពិន (*Barbonymus gonionotus*), ត្រីស្រកាក្តាម (*Cyclocheilichthys apogon*), ត្រីចង្វាជញ្ជក់ដៃ (*Crossocheilus reticulatus*), ត្រីក្រោស (*Crossocheilus atrilimes*), ត្រីចង្វារនោង (*Garra fasciacauda*), ត្រីខ្នាន់ (*Hampala macrolepidota*), ត្រីអាចម៍កុក (*Labiobarbus siamensis*) **និង (២) ត្រីខ្មៅ:** ត្រីរស់ (*Channa Striata*), ត្រី ឆ្តោ (*Channa micropeltes*), ត្រីដំរី (*Oxyeleotris marmorata*), ត្រីកញ្ជនជ័យ (*Channa licius*) ត្រីឆ្លាំង (*Hemibagrus spilopterus*), ត្រីទ្រនេល (*Hemibagrus filamentus*), ត្រីកញ្ចុះ (*Mystus albolineatus*), ត្រីកញ្ចុះ (*Pseudomystus*

*siamensis*) ត្រីកញ្ចុះ (*Mystus atrifasciatus*), ត្រីអណ្តែងងាំង (*Clarias nieuhofii*), ត្រីអណ្តែងរឹង (*Clarias batrachus*), ត្រីស្លាត (*Notopterus notopterus*), ត្រីក្រម៉ម (*Ompok bimaculatus*) ។

## ៥-៤ ធនធានសង្គម និងសេដ្ឋកិច្ច

៨០. លទ្ធផលនៃការធ្វើ PRA មានបង្ហាញនៅទំព័រ ៧៩-៨៩ (កំណត់ហេតុ និងរបាយការណ៍សង្ខេបស្តីពីការពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្តស្រុក មន្ទីរ និងសហគមន៍ពាក់ព័ន្ធ លើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម) ។

## ៥-៥ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

៨១. ក្រៅពីក្នុងទីរួមខេត្ត ដីដែលនៅតាមសងខាងបណ្តោយផ្លូវជាតិលេខ៤៨ និងផ្លូវបែកទៅស្រុកថ្មបាំងច្រើនគឺជនបទ។ ការអភិវឌ្ឍន៍ ផ្នែកសេដ្ឋកិច្ចក្នុងតំបន់នេះមានលក្ខណៈខុស១គ្នាទៅតាមទីប្រជុំជន ខេត្ត ស្រុក និងជនបទ។ ចំណែកឯប្រជាជន ឃុំ ថ្មដូនពៅ និងឃុំជំនាប់ ក្រៅពីការប្រកបរបរធ្វើចំការ និងការរុករកផលអនុផលព្រៃឈើ និងការប្រមាញ់ ក្រោយពីប្រមូលផលស្រូវចំការរួច មានគ្រួសារភាគច្រើនបានធ្វើចំការ (ពោត សណ្តែក ល្ង ដំណាំហូបផ្លែ) ប្រកបរបរលក់ដូរបន្តិចបន្តួច តាមដងផ្លូវជាតិលេខ៤៨ (ទីរួមខេត្តកោះកុង-ទីប្រជុំជនថ្មបាំង និងស្រែអំបិល) សំរាប់បំរើតម្រូវការក្នុងភូមិឃុំ និងអ្នកដំណើរក្នុងតំបន់ និងមកពីចំងាយ ហើយមានគ្រួសារខ្លះ (ជាអ្នកចំណូលថ្មី ដែលភាគច្រើនមកពីខេត្ត កំពង់ចាម តាកែវ បាត់ដំបង) បានដាំដំណាំ និងបន្លែបង្កាបន្តិចបន្តួចក្បែរ១ផ្ទះ (ក្បែរអណ្តូង ខ្ទោះ) សំរាប់ផ្គត់ផ្គង់សេចក្តីត្រូវការក្នុងគ្រួសារ និងដោះដូរជារបស់ផ្សេង១ជាមួយអ្នកភូមិផងរបងជាមួយ។

៨២. តាមរយៈការចុះសិក្សាដោយផ្ទាល់ជាមួយមេឃុំ មេភូមិ នៅទីនោះបានអោយដឹងថា ជីវភាពរស់នៅរបស់ប្រជាជន នៅក្នុងភូមិទាំងមូលដែលជាប់ពាក់ព័ន្ធនឹងតំបន់សម្បទានគឺអាស្រ័យ ទៅលើការធ្វើស្រែ និងចំការដែលពួកគាត់ចាត់ទុកថាជាមុខរបរសំខាន់របស់ពួកគាត់។ ទន្ទឹមនឹងនេះដែរ ដើម្បីបង្រួបភាពខ្វះខាតជីវភាពក្នុងគ្រួសារ ពួកគាត់បានកាប់រានដីព្រៃសំរាប់ធ្វើចំការដាំដំណាំផ្សេង១ ដូចជា: ស្រូវ ឪឡឹក ពោត ដំឡូងជ្វាសណ្តែក ល្ង ជាដើម។ លើសពីនេះទៅទៀត ពួកគាត់បានចូលព្រៃដើម្បីកាប់ កូនឈើ ឈើក្រាក់ អុស រកវល្លិ៍ វាយផ្តៅ រកទំពាំង កាប់ឬស្សី ដងជ័រទឹក បេះផ្សិតឈើ បេះផ្លែឈើ បេះស្លឹកព្រិច បន្លែផ្អែម ។ល។

៨៣. ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេង១គ្នា អាស្រ័យនឹងការប្រកបមុខរបររបស់គ្រួសារនីមួយ១។ សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញដែលការប្រកបរបរ មានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេង១គ្នា។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អាត្រានៃភាពក្រីក្រ នៅក្នុងខេត្តកោះកុងមាន: ៨,២ភាគរយ លើចំនួនប្រជាជនសរុប ១៣០.៥៦២នាក់ ក្នុងនោះមាន ១០៤.០៩៩៨នាក់ ឬស្មើនឹង៨០ភាគ

រយរស់នៅជនបទ (ផែនទីភាព ក្រីក្ររបស់ កម្មវិធីស្បៀងអង្គការសហប្រជាជាតិឆ្នាំ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៤)។ នៅក្នុងខេត្តកោះកុងទាំងមូលចំនួន អ្នកមិនចេះអក្សរសរុប មាន ២១.៩១៧ នាក់ (ក្នុងនោះប្រុស ៩.៣៥៨នាក់ ស្រី ១២.៥៥៩ នាក់)។

៨៤. លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៍ អគ្គិសនី ការផ្គត់ផ្គង់ទឹកស្អាត អប់រំ និងសុខាភិបាល) នៅក្នុងសហគមន៍នេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ។ ការចុះសិក្សាអង្កេតដោយផ្ទាល់បានបង្ហាញថា ផ្លូវគមនាគមន៍ដ៏សំខាន់សំរាប់ប្រជាពលរដ្ឋឃុំជីខលើ ធ្វើដំណើរនិងដឹកជញ្ជូនផ្សេងៗគឺផ្លូវជាតិលេខ៤៨ ដែលមានលក្ខណៈងាយស្រួលក្នុងការដឹកជញ្ជូនទំនិញពីខេត្ត ឯពីស្រុកទៅតាមភូមិក្នុងឃុំទាំងមូលមានលក្ខណៈពិបាក។ ចំពោះ ផ្លូវគមនាគមន៍នៅក្នុងឃុំថ្មដូនពៅ និងឃុំជំនាប់ក៏មានលក្ខណៈជាផ្លូវលំពិបាកធ្វើដំណើរនៅឡើយដែរ គឺចាប់បំបែកចូលរហូតដល់ស្រុកថ្មបាំង និងដល់ឃុំទាំងពីរចម្ងាយ(៧០គ.ម)។ ដោយសារតែការធ្វើ ដំណើរចេញចូលមានលក្ខណៈលំបាកខ្លាំង ដូច្នេះហើយទើបធ្វើអោយការប្រាស្រ័យទាក់ទងរវាងសហគមន៍ទាំងនេះ ជាមួយនឹងតំបន់ខាងក្រៅពុំមានលក្ខណៈទូលំទូលាយ និងទទួលបានការយកចិត្តទុកដាក់តិចតួចពីបណ្តាភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ ដែលក្នុងនោះមានការផ្គត់ផ្គង់ទឹកស្អាត ថាមពលអគ្គិសនី សាលារៀន និងមណ្ឌល សុខភាពជាដើម ។

## ៥-៦ ធនធានសង្គម និងវប្បធម៌

៨៥. ក្រុមការងារធ្វើការសិក្សាវាយតំលៃអំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងភូមិសាស្ត្រដែលក្រុមហ៊ុន Samnang Rea Thborng Thmor Import-Export and Development CO., LTD. បានស្នើសុំ មានទីតាំងស្ថិតក្នុងឃុំថ្មដូនពៅ ឃុំជំនាប់ ស្រុកថ្មបាំង និងឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង។ ការសិក្សាបានបង្ហាញថា ឃុំថ្មដូនពៅ និងឃុំជំនាប់ ស្រុកថ្មបាំង និងក្នុងឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង។ ឃុំថ្មដូនពៅ មានប្រជាជនសរុបចំនួន១០៧គ្រួសារ ស្មើនឹង៤១៣នាក់ ក្នុងនោះមានស្ត្រីចំនួន ២០៥នាក់ រស់នៅក្នុងភូមិចំនួន ០២ គឺ: (១) ភូមិព្រែកស្វាយ មានប្រជាជនរស់នៅ ចំនួន ៦៥គ្រួសារ សរុប២៣២នាក់ ក្នុងនោះស្ត្រីមាន១១៥នាក់ (២) ភូមិកោះ មានប្រជាជនចំនួន ៤២គ្រួសារ សរុប១៨១នាក់ ស្ត្រីមាន ៥២១ នាក់ និងឃុំជំនាប់មានប្រជាជន៧៤គ្រួសារ មនុស្សសរុបចំនួន ៣១៦នាក់ ស្ត្រីមាន១៥៧នាក់ ដែលរស់នៅក្នុងភូមិចំនួន២: (១) ភូមិប្រកឬស្សី មានប្រជាជន ចំនួន ៣៦គ្រួសារ មនុស្សសរុប ១៤៩នាក់ ក្នុងនោះស្ត្រីមាន ៧០ នាក់ (២) ភូមិជំនាប់ មានប្រជាជន ចំនួន ៣៨គ្រួសារ សរុប ១៦៨នាក់ ក្នុងនោះស្ត្រី មាន៨៧នាក់។ ចំណែកឯឃុំជីខលើ មានប្រជាជនចំនួន ១៤១៩គ្រួសារ ស្មើនឹង ៣៤៤៧នាក់ ក្នុងនោះស្ត្រី ១៧០៩នាក់ រស់នៅក្នុងភូមិចំនួន៤គឺ (១) ភូមិជីខ មានប្រជាជន ១៩០គ្រួសារ ស្មើនឹង ៩៧១នាក់ ក្នុងនោះ ស្ត្រី ចំនួន៤៩៤នាក់ (២) ភូមិឈូក មានប្រជាជន ២២៨គ្រួសារ ស្មើនឹង១២២៨នាក់ ក្នុងនោះស្ត្រីចំនួន ៥៩៤នាក់ (៣) ភូមិតានី មានប្រជាជន

១៨១ គ្រួសារ ស្មើនឹង៨៤៦នាក់ ក្នុងនោះស្ត្រីចំនួន ៤៣៤នាក់ (៤) ភូមិ ត្រពាំងកណ្តោល មានប្រជាជន៨២ គ្រួសារ ស្មើនឹង៤០៦នាក់ ក្នុងនោះស្ត្រីចំនួន ១៨៧នាក់ (ស្ថិតិប្រជាជន របស់ឃុំជីខលលើឆ្នាំ២០០៨)។ សូមបញ្ជាក់ផងដែរ ទីតាំងស្នើសុំធ្វើអាជីវកម្មរ៉ែ នេះនៅក្នុងទឹកដីស្រុកថ្មបាំង និងស្រុកស្រែអំបិលមែន ប៉ុន្តែវាមិនពាក់ពន្ធ័នឹងដីភូមិករ និងដីស្រែចំការរបស់ពួកគាត់ទេ គឺស្ថិតនៅឆ្ងាយ ១៦-២០គ.ម ពីភូមិ តែវាអាចពាក់ពន្ធ័ និងការរកចំណូលប្រចាំថ្ងៃដែលពួកគាត់ទទួលបានពីផល និងអនុផលព្រៃឈើ ពីតំបន់នោះ ។

**៨៦.** លំនាំនៃការតាំងទីលំនៅនៅជនបទមានលក្ខណៈ (១) ការតាំងទីលំនៅតាមសងខាងនៃបណ្តោយផ្លូវជាតិលេខ៤៨ និងផ្លូវលំពីផ្លូវ៤៨ទៅថ្មបាំង មានលក្ខណៈរកេតរកូតនិងឃ្លាតពីគ្នាដោយអន្លើៗ ចន្លោះទីរួមខេត្ត និងប្រជុំជនស្រុកថ្មបាំង ស្រុកស្រែអំបិល និង (២) ការតាំងលំនៅដ្ឋានជាលក្ខណៈប្រមូលផ្តុំនៅតាមភូមិក្នុងឃុំថ្មដូនពៅ ឃុំជំនាប់ និងឃុំជីខលើ។

**៨៧.** តាមប្រភពពត៌មានដែលទទួលបានពីមូលដ្ឋានបង្ហាញថា នៅក្នុងទីតាំងតំបន់សម្បទាននេះ ពុំមានសំណាក ឬសំណង់ប្រាសាទប្រវត្តិសាស្ត្រទេ មានតែតំបន់ដែលប្រជាជនក្នុងមូលដ្ឋាននាំគ្នាគោរពបូជា ប៉ុណ្ណោះ តំបន់នេះមាននៅឃុំថ្មដូនពៅ និងឃុំជំនាប់មានព្រៃអារក្សឬព្រៃតំណមចំនួន៥កន្លែងគឺ: ១- តាដូនធំ ២- តាលួង ៣- តាងាម ៤- តាកាំ និង ៥- តាគោហា ដែលមានទំហំពី២-៣ហិតតាប៉ុណ្ណោះ។ ឃុំថ្មដូនពៅមាន ព្រៃអ្នកតានិងព្រៃកប់ខ្មោចក្បែរភូមិចំនួន៣កន្លែង ក្រៅពីនោះក៏នៅមានតំបន់ទេសចរណ៍មួយ ចំនួនទៀតដូចជា ឆាយតាហ៊ីងឆាយអា រ៉ែង នៅតាមដងស្ទឹងអារ៉ែងក្នុងឃុំ តំបន់ត្រីនាគ និងតំបន់ក្រពើភ្នំ។ ចំណែកឯនៅក្នុង ឃុំជីខលើមិនមានតំបន់គ្រប់គ្រងពិសេសទេ មានតែព្រៃតំណមអ្នកតាជជែក (ទំហំ២០ម × ០ម) ដែលប្រជាជនមានជំនឿ តែងតែទៅធ្វើការបន់ស្រន់នៅពេលមានសមាជិកគ្រួសារឈឺស្កាត់ រឺពេលបាត់គោក្របី (ពត៌មានបានពីលោក គង់ ណារិន អ្នកភូមិត្រពាំងកណ្តោល)។

Draft